ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ : ០៥៦/២៤ ក.ប/ស.ស.រ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការវាយតម្លៃ និងជ្រើសរើស សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ

### រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៦/០០៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហជីព
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៨/០១៥ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញប្រកាសលេខ ៣៤២/២៣ ក.ប/ប្រ.ក ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការបង្កើតក្រុមការងាររៀបចំយន្តការវាយតម្លៃសហគ្រាសមួយ ជាសហគមន៍សុខសាន្តមួយ
- បានឃើញប្រកាសលេខ ៣៩៤/២៣ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការកំណត់លក្ខណវិនិច្ឆ័យសហគ្រាសមួយជាសហគមន៍សុខសាន្តមួយ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មការវាយតម្លៃ និងជ្រើសរើសសហគ្រាសមួយជាសហគមន៍សុខសាន្តមួយ ហៅកាត់ថា " **គ.ស.ស.**" ដែលមានសមាសភាពដូចខាងក្រោម៖

**ក-តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

| | | |
|---|---|---|
| ១-រដ្ឋលេខាធិការប្រចាំការ | | ប្រធាន |
| ២-រដ្ឋលេខាធិការទទួលបន្ទុក | ២ (ពីរ) រូប | អនុប្រធាន |
| ៣-អនុរដ្ឋលេខាធិការទទួលបន្ទុក | ២ (ពីរ) រូប | សមាជិក |
| ៤-តំណាងអគ្គលេខាធិការដ្ឋានគណៈកម្មការសម្រាប់ ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា | ១ (មួយ) រូប | សមាជិក |
| ៥-តំណាងអគ្គនាយកដ្ឋានការងារ | ១ (មួយ) រូប | សមាជិក |
| ៦-តំណាងអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ | ១ (មួយ) រូប | សមាជិក |
| ៧-តំណាងបេឡាជាតិសន្តិសុខសង្គម | ១ (មួយ) រូប | សមាជិក |
| ៨-តំណាងអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | ១ (មួយ) រូប | សមាជិក |

**ខ-តំណាងអង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត**

| | | |
|---|---|---|
| ១-តំណាងសហភាពសហជីពមរតកជាតិកម្ពុជា | ១ (មួយ) រូប | សមាជិក |
| ២-តំណាងសហភាពសហព័ន្ធសហជីពជាតិកម្ពុជា | ១ (មួយ) រូប | សមាជិក |
| ៣-តំណាងសហភាពសហជីពយុវជនការពារសិទ្ធិកម្មករកម្ពុជា | ១ (មួយ) រូប | សមាជិក |
| ៤-តំណាងសហភាពសហជីពស្មារតីយុវជនដើម្បីការងារកម្ពុជា | ១ (មួយ) រូប | សមាជិក |
| ៥-តំណាងសហភាពការងារកម្ពុជា | ១ (មួយ) រូប | សមាជិក |
| ៦-តំណាងសហភាពសិទ្ធិកម្មករកម្ពុជា | ១ (មួយ) រូប | សមាជិក |
| ៧-តំណាងសហភាពសហជីពយុវជនកម្មករកម្ពុជា | ១ (មួយ) រូប | សមាជិក |
| ៨-តំណាងសម្ព័ន្ធសហជីពចលនាកម្មករ | ១ (មួយ) រូប | សមាជិក |
| ៩-តំណាងសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា | ១ (មួយ) រូប | សមាជិក |

**គ-តំណាងអង្គការវិជ្ជាជីវៈរបស់និយោជក**

| | | |
|---|---|---|
| ១-តំណាងសភាពាណិជ្ជកម្មកម្ពុជា | ១ (មួយ) រូប | សមាជិក |
| ២-តំណាងសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា | ២ (ពីរ) រូប | សមាជិក |
| ៣-តំណាងសមាគមវាយនភណ្ឌ សម្លៀកបំពាក់ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា | ២ (ពីរ) រូប | សមាជិក |
| ៤-តំណាងសមាគមស្បែកជើងកម្ពុជា | ២ (ពីរ) រូប | សមាជិក |
| ៥-តំណាងសមាគមផលិតផលធ្វើដំណើរ និងស្បែកនៅកម្ពុជា | ១ (មួយ) រូប | សមាជិក |
| ៦-តំណាងសមាគមកាបូប ស្បែកជើង និងអេឡិចត្រូនិកកម្ពុជា | ១ (មួយ) រូប | សមាជិក |

**ឃ-តំណាងភាគីពាក់ព័ន្ធ**

| | | |
|---|---|---|
| ១-តំណាងក្រុមប្រឹក្សាអាជ្ញាកណ្តាល | ១ (មួយ) រូប | សមាជិក |
| ២-តំណាងគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា | ១ (មួយ) រូប | សមាជិក |

**ប្រការ២ .–**

**គ.ស.ស.** មានភារកិច្ចដូចខាងក្រោម៖

- ធ្វើការត្រួតពិនិត្យ វាយតម្លៃ និងជ្រើសរើសសហគ្រាស គ្រឹះស្ថាន ដោយផ្អែកលើវិញ្ញាបនបត្របញ្ជាក់អនុលោមភាពប្រចាំឆ្នាំនីមួយៗ ដើម្បីផ្តល់ពានរង្វាន់ និងវិញ្ញាបនបត្រ "សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ" ទៅតាមកម្រិតចំណាត់ថ្នាក់នៃជ័យលាភី
- ពិនិត្យ និងដោះស្រាយរាល់បណ្តឹងតវ៉ាផ្សេងៗ ពាក់ព័ន្ធនឹងដំណើរការនៃការពិនិត្យ វាយតម្លៃ និងជ្រើសរើស "សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ"
- អនុវត្តភារកិច្ចផ្សេងទៀតតាមការចាត់តាំងរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ៣ .–**

ក្នុងករណីប្រធានអវត្តមាន រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាចទទួលភារកិច្ចជាប្រធានស្តីទីនៃ **គ.ស.ស.** តាមការប្រគល់ភារកិច្ចរបស់ប្រធាន។

សមាជិក សមាជិកានៃ **គ.ស.ស.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីសមាជិក សមាជិកាអវត្តមាន ត្រូវចាត់តំណាងដែលមានសិទ្ធិសម្រេច ដើម្បីចូលរួមប្រជុំតាមការកំណត់។

**ប្រការ៤ .–**

ប្រធាន **គ.ស.ស.** មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ តំណាងសង្គមស៊ីវិល ទីប្រឹក្សា ឬអ្នកជំនាញការជាតិនិងអន្តរជាតិ ឱ្យចូលរួមប្រជុំក្នុងឋានៈជាអ្នកសង្កេតការណ៍ ឬផ្តល់យោបល់ទៅតាមភាពចាំបាច់នៃការងារ។

**ប្រការ៥ .–**

**គ.ស.ស.** មានសិទ្ធិប្រើត្រារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីប្រតិបត្តិការងារក្រោមក្របខណ្ឌនៃសេចក្តីសម្រេចនេះ។

ការចំណាយសម្រាប់ប្រតិបត្តិការការងារវាយតម្លៃរបស់ **គ.ស.ស.** ស្ថិតនៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ៦ .–**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា អគ្គនាយកនៃបេឡាជាតិសន្តិសុខសង្គម និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

ហេង សួរ

**កន្លែងទទួល**:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ